**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**គណៈកម្មការប្រឡងជ្រើសរើសនិស្សិតចូលរៀន**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវះកាត់ មុខមាត់-ឆ្អឹងថ្គាម ជំនាន់ទី១**
**និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពត់ធ្មេញ ជំនាន់ទី៣**
**ឆ្នាំសិក្សា ២០២៣-២០២៤ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល**

លេខ [illegible]

ថ្ងៃ សុក្រ ៩ កើត ខែ ជេស្ឋ ឆ្នាំរោង បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០២៤

# បទបញ្ជាផ្ទៃក្នុង

## សម្រាប់ការប្រឡងជ្រើសរើសបេក្ខជន បេក្ខនារី ចូលរៀន ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវះកាត់ មុខមាត់-ឆ្អឹងថ្គាម ជំនាន់ទី១ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពត់ធ្មេញ ជំនាន់ទី៣ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សម្រាប់ឆ្នាំសិក្សា ២០២៣-២០២៤

ដើម្បីធានាឱ្យការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវះកាត់មុខមាត់-ឆ្អឹងថ្គាម ជំនាន់ទី១ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពត់ធ្មេញ ជំនាន់ទី៣ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ប្រព្រឹត្តទៅដោយភាពត្រឹមត្រូវ យុត្តិធម៌ សមភាព និងតម្លាភាព បេក្ខជន បេក្ខនារីទាំងអស់ត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងសម្រាប់ការប្រឡងដែលមានចែងដូចខាងក្រោម ៖

១- បេក្ខជន បេក្ខនារី ត្រូវគោរពតាមកាលវិភាគប្រឡងដែលបានកំណត់ និងផ្សព្វផ្សាយដោយគណៈកម្មការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវះកាត់មុខមាត់-ឆ្អឹងថ្គាម ជំនាន់ទី១ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពត់ធ្មេញ ជំនាន់ទី៣ នៅស.វ.ស ។

២- បេក្ខជន បេក្ខនារី ត្រូវមកមណ្ឌលប្រឡង **មួយម៉ោង (៦០នាទី) មុនពេលប្រឡង** តាមវេននីមួយៗ ។

៣- បេក្ខជន បេក្ខនារី ដែលមក**យឺតលើសពី១៥នាទី** ក្រោយពេលការប្រឡងចាប់ផ្តើម នឹងមិនត្រូវបានអនុញ្ញាតអោយចូលប្រឡងឡើយ ហើយត្រូវបានចាត់ទុកថា**អវត្តមាន** និងមិនអនុញ្ញាតអោយប្រឡងជាមួយ ក្រុមផ្សេងទៀតឡើយ។

៤- បេក្ខជន បេក្ខនារី ដែល**អវត្តមាន**ក្នុងពេលប្រឡង នឹងត្រូវបានចាត់ទុកថា**ធ្លាក់ជាស្វ័យប្រវត្តិ**។

៥- ហាមយកអាវុធ ឬជាតិផ្ទុះចូលក្នុងបរិវេណមណ្ឌលប្រឡង។

៦- បេក្ខជន បេក្ខនារី ត្រូវមានអាកប្បកិរិយាសមរម្យ និងសម្លៀកបំពាក់និស្សិតក្នុងពេលប្រឡង។

៧- បេក្ខជន បេក្ខនារី ត្រូវយកមកជាមួយនូវ បង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង ដើម្បីបង្ហាញដល់អនុរក្ស មុនពេលចូលប្រឡង។ ក្នុងករណីគ្មានបង្កាន់ដៃនោះទេ បេក្ខជនត្រូវសុំការបញ្ជាក់ និងការអនុញ្ញាតពីអនុគណកម្មការកណ្តាលជាមុនសិន ។

៨- បេក្ខជន បេក្ខនារី មិនត្រូវបានអនុញ្ញាតិឱ្យយក ប៊ិច ក្រដាស់ សំណៅឯកសារ ទូរស័ព្ទដៃ ឬឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ ចូលក្នុងបន្ទប់ប្រឡងជាដាច់ខាត។ គណៈកម្មការប្រឡង មិនទទួលខុសត្រូវលើការបាត់បង់សម្ភារៈនានារបស់បេក្ខជន បេក្ខនារីឡើយ។ ប្រសិនបើអនុរក្សរកឃើញថាមានសម្ភារៈទាំងនោះជាប់ខ្លួនក្នុងពេលប្រឡងត្រូវចាត់ទុកថា **ធ្លាក់ដោយស្វ័យប្រវត្តិ** ។

៩- ការហៅឈ្មោះចូលបន្ទប់ប្រឡង និងផ្ទៀងផ្ទាត់អត្តសញ្ញាណបេក្ខជន បេក្ខនារី នឹងត្រូវធ្វើឡើង**៤០នាទី មុន**ម៉ោងកំណត់ការប្រឡងតាមក្រុមនីមួយៗ ។

១០-បេក្ខជន បេក្ខនារី ត្រូវតម្រង់ជួរចូលក្នុងបន្ទប់ប្រឡងតាមការហៅឈ្មោះពីអនុរក្ស ដោយឆ្លងកាត់ការត្រួតពិនិត្យ និងស្កេនម្រាមដៃដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់បេក្ខជន បេក្ខនារី ។

១១-បេក្ខជន បេក្ខនារី ត្រូវចាប់ឆ្នោតយកលេខកុំព្យូទ័រ ហើយត្រូវចូលទៅកាន់ទីកន្លែងប្រឡងតាមលេខកុំព្យូទ័ររៀងៗខ្លួនតាមការណែនាំរបស់អនុរក្ស។ បេក្ខជន បេក្ខនារី មិនត្រូវអង្គុយប្រឡងខុសទីតាំងលេខកុំព្យូទ័រដែលចាប់ឆ្នោតបានឡើយ លើកលែងករណីមានបញ្ហាបច្ចេកទេសកុំព្យូទ័រ ទើបគណៈកម្មការកណ្តាលពិនិត្យ និងអនុញ្ញាតឱ្យផ្លាស់ប្តូរកុំព្យូទ័រ ។

១២-បេក្ខជន បេក្ខនារី ត្រូវរក្សាសណ្តាប់ធ្នាប់ល្អ និងការស្ងៀមស្ងាត់ក្នុងពេលប្រឡង។ ក្នុងករណីមានបញ្ហាកុំព្យូទ័រ ឬមានបញ្ហាផ្សេងៗទៀតត្រូវលើកដៃជាសញ្ញាប្រាប់ដល់ក្រុមអនុរក្សដើម្បីសុំអន្តរាគមន៍។

១៣-បេក្ខជន បេក្ខនារី ណាដែលសាកសួរគ្នាទៅវិញទៅមក ឬ ផ្តល់ឯកសារឱ្យគ្នាក្នុងពេលប្រឡង ឬធ្វើជាសញ្ញាជាកាយវិការផ្សេងៗ បេក្ខជន បេក្ខនារី នោះ (ទាំងអ្នកផ្តល់ឯកសារ និងអ្នកទទួលឯកសារ ទាំងអ្នកសួរ និងអ្នកប្រាប់ ទាំងអ្នកផ្តល់សញ្ញា និងអ្នកទទួលសញ្ញា) នឹងត្រូវបញ្ឈប់ពីការប្រឡង និងត្រូវធ្លាក់ដោយស្វ័យប្រវត្តិ ។

១៤-ប្រសិនបើគណៈកម្មការរកឃើញថា មានបេក្ខជន បេក្ខនារី ណាមួយត្រូវបានអ្នកផ្សេងមកប្រឡងជំនួស ឬ មកប្រឡងជំនួសឱ្យបេក្ខជនណាម្នាក់ផ្សេង ឈ្មោះបេក្ខជន បេក្ខនារីដែលគេមកប្រឡងជំនួស នោះនឹងត្រូវចាត់ទុកថា**ធ្លាក់ដោយស្វ័យប្រវត្តិ** ។

- បើបេក្ខជន បេក្ខនារី និងជនដែលមកប្រឡងជំនួស ជានិស្សិតកំពុងសិក្សានៅស.វ.ស អ្នកទាំងនោះ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតដែលខ្លួនកំពុងរៀនបច្ចុប្បន្ន និងត្រូវទទួលទោស តាមច្បាប់ជាធរមាន។
- ចំពោះបេក្ខជន បេក្ខនារី និងជនដែលមកប្រឡងជំនួស មិនមែនជានិស្សិតកំពុងសិក្សានៅស.វ.ស អ្នកទាំងនោះនឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

១៥-ករណីដែលបេក្ខជន បេក្ខនារី ប្រព្រឹត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុងចំណុច ១៣ និង១៤ ខាងលើ បេក្ខជន បេក្ខនារី ទាំងនោះត្រូវទទួលការពិន័យដោយមិនអនុញ្ញាតឱ្យប្រឡងចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវះកាត់មុខមាត់-ធ្មេញថ្គាម និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពត់ធ្មេញ នៅស.វ.ស ចំនួន ០២ឆ្នាំជាប់ៗគ្នា។

**គណៈកម្មការរៀបចំការប្រឡង**

**ប្រធាន**

សាស្ត្រាចារ្យ **ឃីត ស៊ុនណារ៉ា**